**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត**

**និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ: ០៦៤ គសអ ផ.ក/២៦

# ផែនការអន្តរស្ថាប័ន

## ស្តីពី

## គោលការណ៍ និងសកម្មភាពរួមក្នុងការត្រៀមរៀបចំផ្លាក់ងារសន្តិសុខបោះឆ្នោត ការពារការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមនីតិកាល និងអាណត្តិនីមួយៗ ចាប់ពីឆ្នាំ២០២៦ ដល់ឆ្នាំ២០៣០

**<u>ឯកសារយោង</u>** ៖

- ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- ព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- ព្រះរាជក្រមលេខ នស/រកម/០៧២៣/០១០ ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោត
- ព្រះរាជក្រឹត្យលេខ នស/រកត/១២២៣/២៥៨៩ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- អនុក្រឹត្យលេខ ២៩១ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (**គ.ស.អ**)
- អនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២៦ ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (**គ.ស.អ**)

- សេចក្តីសម្រេចលេខ ៨៣ សសរ ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២៦ ស្តីពីការតែងតាំងសមាសភាពគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (គ.ស.អ)
- បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ប្រតិទិនសម្រាប់ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិតាមនីតិកាល និងអាណត្តិនីមួយៗ
- បទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ
- ផែនការលេខ ០០១ ផក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៥ របស់ គ.ស.អ ស្តីពីការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សម្រាប់ដំណើរការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត ឆ្នាំ២០២៥ និងឆ្នាំ២០២៦
- សេចក្តីសម្រេចលេខ០២៩ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤ ស្តីពីការបង្កើតលេខាធិការដ្ឋានសន្តិសុខបោះឆ្នោត នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- សេចក្តីសម្រេចលេខ៣៩៩ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលសមាសភាពនៃលេខាធិការដ្ឋានសន្តិសុខបោះឆ្នោត នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងតាមសំណូមពរចាំបាច់នៃការងារ។

អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ត្រូវអនុវត្តការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមនីតិកាល និងអាណត្តិ ឬសម័យបោះឆ្នោតនីមួយៗជាបន្តបន្ទាប់ ដែលដំណើរការរៀបចំនេះត្រូវចាប់ផ្តើមសកម្មភាព ចាប់ពីខែកញ្ញា ឆ្នាំ២០២៦ ដល់ឆ្នាំ២០៣០ តទៅ ៖

- ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ (ចាប់ពីឆ្នាំ២០២៦ ដល់ឆ្នាំ២០៣០)
- ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៦ (នៅថ្ងៃអាទិត្យទី៦ ខែមិថុនា ឆ្នាំ២០២៧)
- ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៨ ឆ្នាំ២០២៨
- ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ (ឬការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា) អាណត្តិទី៥ ឆ្នាំ២០២៩
- ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៦ ឆ្នាំ២០៣០

**រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា** បានសម្រេចបង្កើត គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហៅកាត់ថា «គ.ស.អ» ជាសេនាធិការ ដើម្បីបញ្ជាដឹកនាំកិច្ចការពារការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិគ្រប់នីតិកាល និងអាណត្តិឱ្យប្រព្រឹត្តទៅប្រកបដោយសន្តិសុខ មានសណ្តាប់ធ្នាប់របៀបរៀបរយ និងមានសុវត្ថិភាព គ្មានការភ័យខ្លាច គ្មានការបំភិតបំភ័យ គ្មានការគំរាមកំហែង និងគ្មានអំពើហិង្សាផ្សេងៗ ដោយត្រូវសហការជាមួយ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។

គ.ស.អ មានតួនាទីភារកិច្ចដឹកនាំបញ្ជា តាមដាន ត្រួតពិនិត្យ រៀបចំ គ្រប់គ្រង និងប្រើប្រាស់កម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធ ពិសេសការប្រើប្រាស់កម្លាំងនគរបាល ឬ/និងកងរាជអាវុធហត្ថ ឬ/និងកងយោធពលខេមរភូមិន្ទ ឬ/និងប្រជាការពារ ឱ្យបំពេញភារកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោត តាមផែនការដែលបានកំណត់។

គ.ស.អ សហការជាមួយ គ.ជ.ប ដើម្បីកសាងផែនការអន្តរស្ថាប័នបម្រើឱ្យកិច្ចការពារគ្រប់យុទ្ធនាការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមនីតិកាល និង

អាណត្តិនីមួយៗ។ ដូចនេះ **គ.ស.អ** និង **គ.ជ.ប** សូមដាក់ចេញនូវផែនការអន្តរស្ថាប័ន ស្តីពីគោលការណ៍ និងសកម្មភាពរួមក្នុងការត្រៀមរៀបចំភ្នាក់ងារសន្តិសុខបោះឆ្នោត ការពារការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមនីតិកាល និងអាណត្តិនីមួយៗ ដូចតទៅ៖

## I. គោលបំណង និងសំណូមពរ

### ១. គោលបំណង

ដើម្បីឱ្យយន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៃ គ.ស.អ និង **គ.ជ.ប** រួមនឹងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ពង្រឹងកិច្ចសហការអនុវត្តដោយគោរពតាមបទប្បញ្ញត្តិ និងគោលការណ៍ដូចមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតតាមនីតិកាល និងអាណត្តិនីមួយៗ ផែនការ និងសេចក្តីណែនាំរួម និងដោយឡែក ព្រមទាំងក្រមសីលធម៌សម្រាប់យោធិននៃកងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិ និងក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត។

ធានាបាននូវសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈសម្រាប់ដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងសម័យបោះឆ្នោតនីមួយៗ ឱ្យប្រព្រឹត្តទៅដោយរលូន និងគ្មានការភ័យខ្លាច គ្មានការបំភិតបំភ័យ គ្មានការគំរាមកំហែង និងគ្មានអំពើហិង្សាផ្សេងៗ។

ពិនិត្យរៀបចំ **កម្លាំងនគរបាលជាតិ** ឬ/និង**កងរាជអាវុធហត្ថ** ឬ/និង**កងយោធពលខេមរភូមិន្ទ** ព្រមទាំង **ប្រជាការពារ** ឱ្យបំពេញភារកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោត តាមផែនការដែលបានកំណត់។

ធានាអព្យាក្រឹតភាពក្នុងការផ្តល់សេវាសន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយ និងសុវត្ថិភាពដល់មុខសញ្ញា និងគោលដៅអាទិភាព ដូចមានរៀបរាប់ក្នុងចំណុច II នៃផែនការអន្តរស្ថាប័ននេះ។

### ២. សំណូមពរ

ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវលើការងារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងវិស័យផ្សេងៗទៀត ជាពិសេស យន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវផ្តល់កិច្ចសហការជាដាច់ខាតដល់ **គ.ជ.ប** និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីរក្សាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងសម័យបោះឆ្នោតនីមួយៗឱ្យទទួលបានជោគជ័យ។

យន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសផ្សេងៗ ឬសកម្មភាពបំពារបំពានច្បាប់ផ្សេងៗទៀតដែលជាហេតុបង្កឱ្យមានការភ័យខ្លាច និងប៉ះពាល់ដល់បរិយាកាសនយោបាយ និងសន្តិសុខជាតិទាំងមូល។

តាមសំណើរបស់ **គ.ជ.ប** ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ យន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវយកចិត្តទុកដាក់ការពារសន្តិសុខ សុវត្ថិភាពសម្រាប់គ្រប់ទីកន្លែងរក្សាទុក ការដឹកជញ្ជូនសន្លឹកឆ្នោត សម្ភារ បរិក្ខារ ឯកសារ និងគ្រឿងសង្ហារិមចាំបាច់ផ្សេងៗដែលបម្រើឱ្យការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតនីមួយៗ ប្រកបដោយប្រសិទ្ធភាពខ្ពស់ សុវត្ថិភាព និងគ្មានការរអាក់រអួល។

ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវមានស្មារតីប្រុងប្រយ័ត្ន ពង្រឹង និងកសាងសមត្ថភាព ឈ្វេងយល់ឱ្យបានច្បាស់ អំពីច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតនីមួយៗ និងគោលការណ៍ណែនាំ ផែនការ ឬសេចក្តីណែនាំរួមរវាង **គ.ស.អ** និង **គ.ជ.ប** សេចក្តីណែនាំដោយឡែក ស្តីពីកិច្ចការពារសន្តិសុខបោះឆ្នោត និងក្រមសីលធម៌របស់ **គ.ជ.ប** សម្រាប់ធ្វើជាមូលដ្ឋាននៅក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន។

II. **មុខសញ្ញា និងគោលដៅដែលត្រូវការពារ**

យន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវចាត់ចែងភ្នាក់ងារសន្តិសុខបោះឆ្នោតដើម្បីឱ្យការពារមុខសញ្ញា និងគោលដៅសំខាន់ៗ តាមសំណូមពរចាំបាច់របស់ **គ.ជ.ប** ឬ/និង គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។ មុខសញ្ញា ឬគោលដៅទាំងឡាយគួរត្រូវបានការពារជារួម ឬប្រយោលស្របតាមវិជ្ជាជីវៈ និងជំនាញស្របតាមលទ្ធភាព និងធនធានសមស្របជាក់ស្តែង។

**១. មុខសញ្ញាការពារជាអាទិភាព**

- ប្រធាន អនុប្រធាន និងសមាជិក **គ.ជ.ប** ព្រមទាំងមន្ត្រីរាជការ និងមន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ទាំងអស់នៅទីស្តីការ **គ.ជ.ប**
- ប្រធាន អនុប្រធាន និងសមាជិក **គធ.ខប** ឬ **លធ.ខប** ព្រមទាំងមន្ត្រីរាជការ និងមន្ត្រីបោះឆ្នោតទាំងអស់របស់ **លគធ.ខប** ឬ **លធ.ខប**
- ក្រុមប្រឹក្សាឃុំ សង្កាត់ (**កបឃ.ស**) ស្មៀន និងក្រុមចុះឈ្មោះបោះឆ្នោត (**ក.ច.ប**)
- សមាសភាព គឃ.សប និងសមាសភាព គ.ក.ប/គ.ក.រ
- ប្រជាពលរដ្ឋទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ
- អ្នកបោះឆ្នោត និងអង្គបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាដែលជាតំណាងរាស្ត្រក្នុងតំណែង និងសមាជិក កបឃ.ស ក្នុងតំណែងទាំងអស់នៅក្នុងមណ្ឌលបោះឆ្នោតនោះ
- អ្នកបោះឆ្នោតសម្រាប់ការបោះឆ្នោតអសកល ជ្រើសរើសក្រុមប្រឹក្សា ឬការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គឺសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់នៅក្នុងមុខតំណែង
- គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បេក្ខជន និងអ្នកគាំទ្រ
- អ្នកបោះឆ្នោត (ការបោះឆ្នោតជាសកល)
- ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោតនៃសមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ភ្ញៀវពិសេស អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ដែលទទួលបានការអនុញ្ញាតពី **គ.ជ.ប**
- តំណាងរបស់អង្គការមិនមែនរដ្ឋាភិបាល ឬប្រទេសនានា និងអង្គការអន្តរជាតិ ដែលត្រូវបានអញ្ជើញ និងទទួលស្គាល់ដោយរាជរដ្ឋាភិបាលហើយនឹងអនុញ្ញាតដោយ **គ.ជ.ប** ឱ្យចូលរួមជាអ្នកសង្កេតការណ៍។

**២. គោលដៅការពារជាអាទិភាព**

- ទីស្តីការរបស់ **គ.ជ.ប** ទីស្នាក់ការរបស់ **គធ.ខប** ឬ **លធ.ខប** និងទីស្នាក់ការរបស់ **គឃ.សប**
- ការិយាល័យពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដែលមានទីតាំងនៅតាមសាលាឃុំ សង្កាត់ ឬចល័តតាមភូមិនានាក្នុងឃុំ សង្កាត់ សម្រាប់ការបោះឆ្នោតសកល
- ការិយាល័យចុះឈ្មោះសម្រាប់ការបោះឆ្នោតអសកល
- ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

- ទីតាំងបិទផ្សាយបញ្ជីបោះឆ្នោត បញ្ជីទីតាំងការិយាល័យបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត
- ទីតាំងរោងពុម្ពផលិតសន្លឹកឆ្នោត
- កន្លែងរក្សាទុក ឬទីតាំងពិនិត្យផ្ទៀងផ្ទាត់លទ្ធផលបោះឆ្នោត ឬការដឹកជញ្ជូនសម្ភារ បរិក្ខារ និងសង្ហារិមបម្រើការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោតនីមួយៗ ឯកសារបោះឆ្នោត សន្លឹកឆ្នោត និងកំណត់ហេតុបូកសរុបលទ្ធផលបោះឆ្នោតពីគោលដៅមួយទៅគោលដៅមួយដែលកំណត់ដោយ **គ.ជ.ប** ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- ទីស្នាក់ការ និងកន្លែងជួបប្រជុំ ឬក្បួនព្យុហយាត្រាឃោសនារបស់គណបក្សនយោបាយ ឬបេក្ខជនរបស់គណបក្សនយោបាយ។

### III. វង្វង់ការពារសន្តិសុខការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗត្រូវបានកំណត់ឱ្យមានបរិវេណខាងក្នុង និងបរិវេណខាងក្រៅ។ ១.បរិវេណខាងក្នុង គឺជាតំបន់ដែលនៅជុំវិញការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតខណ្ឌដោយរង្វង់មណ្ឌលមួយ មានកាំប្រវែងយ៉ាងតិច ១៥ ម៉ែត្រ ២.បរិវេណខាងក្រៅ គឺជាតំបន់នៅជុំវិញការិយាល័យទាំងនោះ ខណ្ឌដោយរង្វង់មណ្ឌលមួយដែលមានកាំប្រវែង ១០០ ម៉ែត្រ ឬមានទម្រង់ផ្សេង ឬមានកាំតូចជាងស្រប ទៅតាមស្ថានភាពជាក់ស្តែងនៃភូមិសាស្ត្របរិវេណខាងក្រៅរបស់ការិយាល័យនីមួយៗនោះ។




**គំនូសបរិវេណខាងក្នុង-ខាងក្រៅ**
**នៃការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត**

❖ **<u>កំណត់ចំណាំ</u>**

○ រង្វង់មណ្ឌលកាំប្រវែង ១៥ ម៉ែត្រ គឺជាបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

● រង្វង់មណ្ឌលកាំប្រវែង ១០០ ម៉ែត្រ គឺជាបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត




**គំនូសរង្វង់ការពារសន្តិសុខ**
**នៃការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត**

❖ **កំណត់ចំណាំ**

- ភ្នាក់ងារសន្តិសុខបោះឆ្នោត ក្នុងសម្លៀកបំពាក់ឯកសណ្ឋានត្រឹមត្រូវ និងមានពាក់ប្រឡង់ដៃសម្រាប់សម្គាល់ភ្នាក់ងារសន្តិសុខបោះឆ្នោតដែលកំណត់ដោយ **គ.ជ.ប**។

ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវពិនិត្យរង្វង់ការពារសន្តិសុខនៃការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗឱ្យបានច្បាស់លាស់ និងចាត់វិធានការការពារសន្តិសុខតាមគំនូសបង្ហាញ ដូចរូបភាពខាងលើ។

ការកំណត់ចំនួនកម្លាំងនៃភ្នាក់ងារសន្តិសុខបោះឆ្នោត នៅតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ៖

- ភ្នាក់ងារសន្តិសុខបោះឆ្នោត **(ចំនួនមិនលើសពី ៣នាក់)** ដែលការពារតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗត្រូវស្លៀកពាក់ឯកសណ្ឋានឱ្យបានត្រឹមត្រូវ និងពាក់ប្រឡង់ដៃសម្គាល់ភ្នាក់ងារសន្តិសុខបោះឆ្នោតដែលកំណត់ដោយ **គ.ជ.ប** និងអនុវត្តតាមការណែនាំដូចខាងក្រោម ៖

- ករណីការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតច្រើនប្រមូលផ្តុំនៅក្នុងបរិវេណ ឬអាគារមួយចំនួន ភ្នាក់ងារសន្តិសុខបោះឆ្នោត សម្រាប់ការិយាល័យទាំងនោះត្រូវមានចំនួនសមស្របទៅនឹងស្ថានភាពភូមិសាស្ត្រ និងសន្តិសុខជាក់ស្តែង។

- ភ្នាក់ងារសន្តិសុខបោះឆ្នោត ១នាក់ ត្រូវការពារនៅជុំវិញការិយាល័យ ឬនៅក្នុងបរិវេណខាងក្រៅនៃការិយាល័យ ស្ថិតក្នុងចម្ងាយពី ១៥ ទៅ ១០០ ម៉ែត្រ ពីការិយាល័យ និងមិនចាំបាច់ប្រើប្រាស់អាវុធ

- ភ្នាក់ងារសន្តិសុខបោះឆ្នោត ២នាក់ ត្រូវការពារនៅជុំវិញបរិវេណខាងក្រៅនៃការិយាល័យ ស្ថិតក្នុងចម្ងាយពី ១០០ ទៅ ១៥០ ម៉ែត្រ និងអាចប្រើប្រាស់អាវុធវែង ១ ដើម ដែលមានគ្រាប់យ៉ាងច្រើន ៣០ គ្រាប់។

❖ <u>កំណត់សម្គាល់</u>

**គឺមានតែភ្នាក់ងារសន្តិសុខបោះឆ្នោត (ចំនួនមិនលើសពី ៣នាក់) ដែលការពារនៅតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតឱ្យបំពាក់ប្រឡង់ដៃសន្តិសុខរបស់ គ.ជ.ប នៅពេលដែលកំពុងបំពេញភារកិច្ចការពារការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។**

## IV. យន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងកិច្ចសហការ

### ១. យន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ជាតិ

**គ.ស.អ** គឺជាសេនាធិការជូនរាជរដ្ឋាភិបាល ដើម្បីដឹកនាំបញ្ជា តាមដាន ត្រួតពិនិត្យ រៀបចំ គ្រប់គ្រង និងប្រើប្រាស់កម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីការពារការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គ្រប់នីតិកាល ឬ/និងអាណត្តិ។

**គ.ស.អ** មានលេខាធិការដ្ឋានមួយជាជំនួយការ។ សមាសភាព និងភារកិច្ចរបស់លេខាធិការដ្ឋាននេះត្រូវកំណត់តាមសេចក្តីសម្រេចរបស់ប្រធាន **គ.ស.អ** ដែលមានទីបញ្ជាការរួម ឬទីប្រចាំបញ្ជានៅអគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ។

**លេខាធិការដ្ឋាននៃ គ.ស.អ** ត្រូវបង្កើតឱ្យមានក្រុមប្រចាំការអចិន្ត្រៃយ៍ជាជំនួយការ។ សមាសភាព និងភារកិច្ចរបស់ក្រុមប្រចាំការអចិន្ត្រៃយ៍ត្រូវកំណត់តាមសេចក្តីសម្រេចរបស់ប្រធានលេខាធិការដ្ឋាននៃ **គ.ស.អ**។

### ២. យន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ក្រោមជាតិ

គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលមានស្រាប់ត្រូវបានកំណត់ជាស្វ័យប្រវត្តិជាយន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ក្រោមជាតិ ឬថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដោយមានតួនាទីគ្រប់គ្រង ដឹកនាំបញ្ជា និងត្រួតពិនិត្យលើការអនុវត្តរបស់ភ្នាក់ងារសន្តិសុខបោះឆ្នោត ដែលការពារដំណើរការរៀបចំការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គ្រប់នីតិកាល ឬអាណត្តិ ដោយបំពេញមុខងារតាមឋានៈតួនាទី និងការទទួលខុសត្រូវក្នុងដែនសមត្ថកិច្ចនៃរាជធានី ខេត្តរៀងៗខ្លួន។

គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ដែលមានស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ធ្វើជាសេនាធិការត្រូវគ្រប់គ្រង ដឹកនាំ និងបញ្ជាគ្រប់យន្តការ និងរចនាសម្ព័ន្ធក្រោមឱវាទ ដោយសហការត្រួតពិនិត្យលើការងាររៀបចំចាត់តាំងភ្នាក់ងារសន្តិសុខបោះឆ្នោត ឱ្យបានត្រឹមត្រូវតាមផែនការដែលបានកំណត់។ ជាមួយគ្នានេះដែរ គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្តនីមួយៗ ត្រូវបង្កើតឱ្យមានក្រុមប្រចាំការអចិន្ត្រៃយ៍ជាជំនួយការ ដែលសមាសភាព និងភារកិច្ចរបស់ក្រុមប្រចាំការអចិន្ត្រៃយ៍នេះត្រូវកំណត់តាមសេចក្តីសម្រេចរបស់ប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ។

កម្លាំងនគរបាល ឬ/និងកងរាជអាវុធហត្ថ ឬ/និងកងយោធពលខេមរភូមិន្ទ ឬ/និងប្រជាការពារ ដែលមានមូលដ្ឋានឈរជើងក្នុងទីតាំងភូមិសាស្ត្ររាជធានី ខេត្តនីមួយៗ ត្រូវបានស្នើសុំរៀបចំជាភ្នាក់ងារសន្តិសុខបោះឆ្នោតតាមផែនការកំណត់ និងតាមសំណូមពរចាំបាច់របស់ **គ.ជ.ប** ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។

ជាទូទៅយើងត្រូវប្រើប្រាស់កម្លាំងនគរបាលដើម្បីឱ្យការពារផ្ទាល់តាមគោលដៅសំខាន់ៗជាអាទិភាព ប៉ុន្តែក្នុងករណីខ្វះកម្លាំងនគរបាល ចំនួនកម្លាំងនគរបាលដែលខ្វះទាំងនោះនឹងត្រូវបំពេញដោយកងរាជអាវុធហត្ថ ឬ/និងកងយោធពលខេមរភូមិន្ទ ឬ/និងប្រជាការពារ ដែលទទួលបានការបណ្តុះបណ្តាលជាភ្នាក់ងារសន្តិសុខបោះឆ្នោត។

### ៣. កិច្ចសហការរវាងយន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតនៃ គ.ស.អ និង គ.ជ.ប

កិច្ចការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសម្រាប់ការពារការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គ្រប់នីតិកាល ឬអាណត្តិ គឺជាភារកិច្ចចម្បងសំខាន់ដែលគ្រប់យន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់បំផុត និងប្រកបដោយការទទួលខុសត្រូវ។

យន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវផ្តើមសកម្មភាពចាប់ពីដំណាក់កាលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត ការបោះឆ្នោត និងរាប់សន្លឹកឆ្នោត រហូតដល់ការប្រកាសលទ្ធផលបោះឆ្នោតផ្លូវការត្រូវបានបញ្ចប់សព្វគ្រប់ជាស្ថាពរ។

**គ.ស.អ** និង **គ.ជ.ប** ត្រូវចេញសេចក្តីណែនាំរួម ស្តីពីវិធានការចាំបាច់នានាពាក់ព័ន្ធដល់ការធានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈសម្រាប់ដំណើរការរៀបចំការបោះឆ្នោតតាមគ្រប់ដំណាក់កាល ដោយគិតទាំងវិធីសាស្ត្រនៃការដាក់ពង្រាយកម្លាំងភ្នាក់ងារសន្តិសុខបោះឆ្នោតសម្រាប់ការបោះឆ្នោតផង។

ស្ថិតក្នុងដែនសមត្ថកិច្ចដែនដីរៀងៗខ្លួន ប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ត្រូវម្ចាស់ការទទួលខុសត្រូវខ្ពស់ និងសហការជាមួយ **គ.ជ.ប** ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។

**គំនូសបន្ទាញ អំពីកិច្ចសហការផ្នែកការងារសន្តិសុខបោះឆ្នោត**




## V. គោលការណ៍នៃការរៀបចំកម្លាំងភ្នាក់ងារសន្តិសុខបោះឆ្នោត

សម្រាប់ការពារការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិតាមនីតិកាល និងអាណត្តិនីមួយៗ ការរៀបចំកម្លាំង និងភារកិច្ចរបស់ភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធភ្ជាប់ ៣ ដូចខាងក្រោម៖

- **ក. ឧបសម្ព័ន្ធ-១** ការរៀបចំកម្លាំង និងភារកិច្ចរបស់ភ្នាក់ងារសន្តិសុខបោះឆ្នោត ការពារការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ
- **ខ. ឧបសម្ព័ន្ធ-២** ការរៀបចំកម្លាំង និងភារកិច្ចរបស់ភ្នាក់ងារសន្តិសុខបោះឆ្នោត ការពារការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៦ ឆ្នាំ២០២៧ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៨ ឆ្នាំ២០២៨

**គ. ឧបសម្ព័ន្ធ-៣** ការរៀបចំកម្លាំង និងភារកិច្ចរបស់ភ្នាក់ងារសន្តិសុខបោះឆ្នោតការពារការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៥ ឆ្នាំ២០២៩ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៦ ឆ្នាំ២០៣០

## VI. ការចាត់តាំងអនុវត្ត

**១. គ.ស.អ** គឺជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការត្រួតពិនិត្យ តាមដាន រំលឹកដាស់តឿន និងត្រូវចាត់ចែងគ្រប់សកម្មភាពរបស់ភ្នាក់ងារសន្តិសុខបោះឆ្នោត ក្នុងពេលពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងក្នុងសម័យបោះឆ្នោតនីមួយៗ រហូតចប់ភារកិច្ច។

**២.** ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ពិសេសយន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវផ្តល់កិច្ចសហប្រតិបត្តិការជាដាច់ខាតឱ្យបានជាប់ជាប្រចាំ និងទាន់ពេលវេលាជាមួយ **គ.ជ.ប** និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដោយត្រូវបង្កើនការផ្លាស់ប្តូរព័ត៌មានអំពីសភាពការណ៍សន្តិសុខ ឬការងារផ្សេងៗទៀត ក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងក្នុងសម័យបោះឆ្នោតនីមួយៗ។

**៣.** ក្នុងករណីមានបទល្មើសជាក់ស្តែង ឬឧបទ្ទវហេតុអ្វីមួយកើតឡើង ក្រសួង ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចត្រូវយកចិត្តទុកដាក់ស្រាវជ្រាវស៊ើបអង្កេតរកឱ្យឃើញ និងកំណត់អត្តសញ្ញាណជនល្មើសឱ្យបានច្បាស់ ដោយត្រូវចាប់ឃាត់ខ្លួន ឬស្វែងរកចាប់ខ្លួនជនល្មើសដែលប្រព្រឹត្តបទល្មើសជាក់ស្តែង ឬក៏តាមដីកាសម្រេចរបស់ស្ថាប័នតុលាការយកមកផ្តន្ទាទោសតាមច្បាប់ជាធរមាន ទោះបីជនប្រព្រឹត្តល្មើសនោះមានឋានៈខ្ពស់ និងស្ថិតក្នុងក្របខ័ណ្ឌ ឬគណបក្សនយោបាយណាក៏ដោយ។

**៤.** ក្នុងសម័យបោះឆ្នោតនីមួយៗ **គ.ស.អ** ត្រូវសហការជាមួយ **គ.ជ.ប** ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលតាមការចាំបាច់ អំពីច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ក្រមសីលធម៌សម្រាប់យោធិននៃកងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិ ដល់គ្រូបង្គោលនៃអង្គភាពកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងនគរបាលជាតិ និងដល់មន្ត្រីអនុវត្តច្បាប់ដទៃទៀត រួមទាំងប្រជាការពារដែលទទួលភារកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោត។

**៥.** គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្នុងនាមជាយន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ក្រោមជាតិ ឬថ្នាក់រាជធានី ខេត្ត ត្រូវ ៖

- ប្រើប្រាស់ធនធានមនុស្ស សម្ភារ និងមធ្យោបាយដែលមានស្រាប់ និងស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្តាប់ជាប់សភាពការណ៍ ផែនការ និងឧបាយកលបង្កអំពើវិទ្ធង្សនា ឬវិច្ឆេទកម្ម ភេរវកម្មជាតិ និងអន្តរជាតិ ឃាតកម្ម ការចាប់ជម្រិត ការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា អំពើឆក់ ប្លន់ ចោរកម្ម សកម្មភាពក្មេងទំនើង ។ល។ ដែលនឹងបង្កឱ្យមានព្យសនកម្មប៉ះពាល់ ឬអន្តរាយដល់ទ្រព្យសម្បត្តិ និងអាយុជីវិតរបស់ប្រជាពលរដ្ឋស្លូតត្រង់ ដោយត្រូវដាក់ចេញជាវិធានការបង្ការ រាំងស្កាត់ និងបង្ក្រាបឱ្យបានតឹងរ៉ឹងនៅតាមភូមិសាស្ត្រដែលខ្លួនត្រូវទទួលខុសត្រូវ។
- រៀបចំក្រុមប្រតិកម្មរហ័សដើម្បីឆ្លើយតប បកស្រាយ ឬ/និងវាយបកទាន់ពេលវេលា ចំពោះការបំពុលព័ត៌មាននានា ដើម្បីជានាបរិយាកាសបោះឆ្នោត ដូចជាការបំពុលព័ត៌មានបង្កចលាចលក្នុងសង្គម ធ្វើឱ្យប៉ះពាល់ដល់បរិយាកាសនៃយុទ្ធនាការបោះឆ្នោត។

- មានភារកិច្ចទទួលខុសត្រូវដោយផ្ទាល់ ដាក់ចេញផែនការសកម្មភាព និងចាត់វិធានការផ្សេងៗ ដើម្បីត្រួតពិនិត្យតាមដានរំលឹកដាស់តឿន និងចាត់ចែងប្រគល់ភារកិច្ចដល់កម្លាំងមានសមត្ថកិច្ច ឬអាជ្ញាធរដែនដីក្រោមឱវាទទាំងអស់ ពិសេសសកម្មភាពអនុវត្តការងាររបស់ភ្នាក់ងារសន្តិសុខបោះឆ្នោត ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងក្នុងសម័យបោះឆ្នោតនីមួយៗ។
- ជំរុញអនុវត្តបន្ថែមទៀតនូវ «**គោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព**» ដែលជាកម្លាំងចលករមួយយ៉ាងសំខាន់ក្នុងការជួយពង្រឹងដល់ខឿនសន្តិសុខ ការរក្សាសណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ និងសុវត្ថិភាពសង្គមឱ្យកាន់តែមានលក្ខណៈល្អប្រសើរឡើង។
- មានកិច្ចសហប្រតិបត្តិការល្អ និងធ្វើការសម្របសម្រួលឱ្យបានជាប់ជាប្រចាំជាមួយលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (**លធ.ខប**) ក្រុមប្រឹក្សាឃុំ សង្កាត់ (**កបឃ.ស**) និងស្មៀន និងក្រុមចុះឈ្មោះបោះឆ្នោត (**ក.ច.ប**) នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ចំណែកក្នុងសម័យបោះឆ្នោតនីមួយៗ ត្រូវសហការជាមួយគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (**គធ.ខប**) គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (**គឃ.សប**) គណៈកម្មការការិយាល័យបោះឆ្នោត (**គ.ក.ប**) និងគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត (**គ.ក.រ**) រហូតចប់ភារកិច្ចជាស្ថាពរ។
- ត្រូវសហការជាមួយ **គធ.ខប** និងគ្រូបង្គោលដែលបានទទួលការបណ្តុះបណ្តាលនៅថ្នាក់ជាតិ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលតាមការចាំបាច់ ស្តីពីច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ក្រមសីលធម៌សម្រាប់យោធិននៃកងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោត ក្នុងដំណើរការបោះឆ្នោតដល់មន្ត្រីអនុវត្តច្បាប់ និងកងកម្លាំងប្រដាប់អាវុធរួមទាំងប្រជាការពារដែលទទួលភារកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោត។
- ដោយឡែកចំពោះការរៀបចំវគ្គបណ្តុះបណ្តាលអំពីការងារបោះឆ្នោត ដែលត្រូវរៀបចំដោយ **គធ.ខប** ឬ **លធ.ខប** ត្រូវអញ្ជើញតំណាង ឬគ្រូបង្គោលនៃអង្គភាពកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងស្នងការដ្ឋាននគរបាលរាជធានី ខេត្តនីមួយៗឱ្យចូលរួម។

**៦.** ក្នុងកម្លាំងអនុវត្តច្បាប់ដែលចូលរួមក្នុងកិច្ចប្រតិបត្តិការការពារនេះ គឺជាអ្នកអនុវត្តផ្ទាល់ ត្រូវស្ថិតក្រោមការដឹកនាំបញ្ជាតាមឋានានុក្រមនៃអង្គភាពរៀងៗខ្លួនផ្អែកលើផែនការកំណត់ និងគោលការណ៍ច្បាប់ជាមូលដ្ឋានដោយមិនត្រូវបង្កបាតុភាពផ្សេងៗ ឬក៏ធ្វើសកម្មភាពអ្វីដោយគ្មានការដឹកនាំបញ្ជាឡើយ។ ក្នុងកិច្ចប្រតិបត្តិការទាំងអស់កម្លាំងមានសមត្ថកិច្ច ត្រូវចៀសវាងការប្រើប្រាស់រូបភាពប្រដាប់អាវុធគគ្រឹកគគ្រេង លើកលែងតែចំពោះករណីមានបទបញ្ជាដែលត្រូវបញ្ចេញកម្លាំងអន្តរាគមន៍ជាបន្ទាន់ និងចាំបាច់ នៅក្នុងពេលមានហេតុការណ៍អសន្តិសុខកើតឡើងដោយចៃដន្យ។

**៧.** ប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ស្នងការនគរបាលរាជធានី ខេត្ត មេបញ្ជាការកងរាជអាវុធហត្ថរាជធានី ខេត្ត មេបញ្ជាការតំបន់សឹករង និងមេបញ្ជាការយោធភូមិភាគដែលពាក់ព័ន្ធត្រូវចូលរួម ឬចាត់តំណាងឱ្យចូលរួមក្នុងគ្រប់កិច្ចប្រជុំតាមការអញ្ជើញរបស់ **គធ.ខប** ឬ **លធ.ខប** ក្នុងគោលដៅពិភាក្សាការងារចាត់វិធានការបង្ការ ទប់ស្កាត់ ឬការស្វែងរកដំណោះស្រាយសមស្រប ដើម្បីកាត់បន្ថយបញ្ហាទំនាស់ ឬបាតុភាពនានាដែលអាចនឹងកើតមាននៅគ្រប់ដំណាក់កាលនៃការរៀបចំការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងក្នុងសម័យបោះឆ្នោតម្តងៗ។

៨. ប្រធានតាមថ្នាក់នីមួយៗ ត្រូវអនុវត្តរបបរាយការណ៍ឱ្យបានទៀតទាត់ ក្នុងករណីចាំបាច់ត្រូវរាយការណ៍ជាបន្ទាន់ជូនថ្នាក់លើតាមឋានានុក្រម ដើម្បីមានវិធានការដោះស្រាយឱ្យទាន់ពេលវេលា និងតាមនីតិវិធីកំណត់។

ផែនការអន្តរស្ថាប័នស្តីពីគោលការណ៍ និងសកម្មភាពរួមក្នុងការត្រៀមរៀបចំភ្នាក់ងារសន្តិសុខបោះឆ្នោត ការពារការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមនីតិកាល និងអាណត្តិនីមួយៗ មានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១៥កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០២៦

**ឋ.គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត** **ឋ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន** **ប្រធាន**

**អភិសន្តិបណ្ឌិត ស សុខា** **ប្រាជ្ញ ចន្ទ**

<u>កន្លែងទទួល</u> ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធ ១

## ការរៀបចំកម្លាំង និងភារកិច្ចរបស់ផ្លាក់ងារសន្តិសុខបោះឆ្នោត ដើម្បីការពារការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ (ឆ្នាំ២០២៦ ឆ្នាំ២០២៧ ឆ្នាំ២០២៨ ឆ្នាំ២០២៩ និងឆ្នាំ២០៣០)

គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្នុងនាមជាយន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ក្រោមជាតិ ឬថ្នាក់រាជធានី ខេត្ត ដែលមានស្នងការដ្ឋាននគរបាលជាជំនួយការ ត្រូវសហការជាមួយ **លធ.ឧប** ដើម្បីត្រៀមរៀបចំភ្នាក់ងារសន្តិសុខបោះឆ្នោត តាមគោលការណ៍កំណត់ដូចតទៅ៖

**I. អំពីការរៀបចំភ្នាក់ងារសន្តិសុខបោះឆ្នោត**

**១. កម្លាំងការពារពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត**

**១.១ កម្លាំងការពារការិយាល័យចុះឈ្មោះបោះឆ្នោត**

**ក-គោលដៅការពារ** : ការិយាល័យចុះឈ្មោះបោះឆ្នោត ដែលមានទីតាំងនៅតាមសាលា ឃុំ សង្កាត់ ឬចល័តតាមភូមិនានាក្នុងឃុំ សង្កាត់

**ខ-ចំនួនកម្លាំងដែលត្រូវប្រើប្រាស់**

: ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់នីមួយៗ ចំនួន ២នាក់

**គ-រយៈពេលការពារ** : ២០-២៥ថ្ងៃ សម្រាប់ការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ឬ ៥៥ថ្ងៃ សម្រាប់ឆ្នាំដែលមានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឬការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ (រយៈពេលអាចមានការប្រែប្រួល តាមការសម្រេចរបស់ **គ.ជ.ប**)

**១.២ កម្លាំងត្រៀមអន្តរាគមន៍ភូមិសាស្ត្រខាងក្រៅ ក្នុងក្រុង ស្រុក ខណ្ឌ**

**ក-គោលដៅត្រៀម** : គ្រប់ក្រុង ស្រុក ខណ្ឌ

**ខ-ចំនួនកម្លាំងដែលត្រូវប្រើប្រាស់**

: អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌនីមួយៗ ចំនួន ១០នាក់

: មូលដ្ឋានកងរាជអាវុធហត្ថក្រុង ស្រុក ខណ្ឌនីមួយៗ ចំនួន ១០នាក់

**គ-រយៈពេលត្រៀម** : ២០ ទៅ ២៥ថ្ងៃ សម្រាប់ការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ឬ ៥៥ថ្ងៃ សម្រាប់ឆ្នាំដែលមានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឬការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ (រយៈពេលអាចមានការប្រែប្រួល តាមការសម្រេចរបស់ **គ.ជ.ប**)

**២. ក្រុមការីវិទ្យុទាក់ទង**

**ក-គោលដៅប្រចាំការ** : គ្រប់រាជធានី ខេត្ត និងគ្រប់ក្រុង ស្រុក ខណ្ឌ

**ខ-ចំនួនកម្លាំងដែលត្រូវប្រើប្រាស់**

: ស្នងការដ្ឋាននគរបាលរាជធានី ខេត្តនីមួយៗ ចំនួន ៤នាក់

: អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌនីមួយៗ ចំនួន ២នាក់

**គ-រយៈពេលប្រចាំការ** : គិតពីពេលចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត រហូតចប់ការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតផ្លូវការប្រចាំឆ្នាំនីមួយៗ

## ៣. កម្លាំងត្រៀមអន្តរាគមន៍នៅនឹងកន្លែង

**ក-គោលដៅត្រៀម** : គ្រប់រាជធានី ខេត្ត នៅទូទាំងប្រទេស

**ខ-ចំនួនកម្លាំងដែលប្រើប្រាស់**

: អគ្គស្នងការដ្ឋាននគរបាលជាតិ ចំនួន ៥០០នាក់

: ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ចំនួន ១២០នាក់

: ស្នងការដ្ឋាននគរបាលខេត្តនីមួយៗ ចំនួន ៦០នាក់

**គ-រយៈពេលត្រៀម** : គិតពីពេលចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត រហូតចប់ការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតផ្លូវការប្រចាំឆ្នាំនីមួយៗ

## II. អំពីភារកិច្ចរបស់ភ្នាក់ងារសន្តិសុខបោះឆ្នោត

ក្នុងអំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ភ្នាក់ងារសន្តិសុខបោះឆ្នោត គឺជាកម្លាំងអនុវត្តដោយផ្ទាល់ ត្រូវសហការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ (**កបឃ.ស**) និងស្មៀន និងក្រុមចុះឈ្មោះបោះឆ្នោត (**ក.ច.ប**) ដើម្បីបំពេញភារកិច្ចតាមការណែនាំ ដូចខាងក្រោម៖

- ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវចាត់វិធានការការពារទីតាំងបិទផ្សាយបញ្ជីបោះឆ្នោត បញ្ជីការិយាល័យបោះឆ្នោត បញ្ជីបោះឆ្នោតដំបូង និងការពារគ្រប់ការិយាល័យចុះឈ្មោះបោះឆ្នោត ឬកន្លែងកំណត់សម្រាប់ចុះឈ្មោះបោះឆ្នោត ដែលចល័តតាមភូមិនានាក្នុងឃុំ សង្កាត់។

- ចំពោះភ្នាក់ងារសន្តិសុខបោះឆ្នោត ២នាក់ ដែលការពារនៅតាមការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗ ត្រូវមានមុខមុនម៉ោង ៧:០០ព្រឹក ដើម្បីពិនិត្យទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ស្ថានភាពសន្តិសុខ និងចាត់វិធានការការពារឱ្យបានតឹងរ៉ឹង។

- ក្នុងពេលបំពេញភារកិច្ច ភ្នាក់ងារសន្តិសុខបោះឆ្នោត មិនត្រូវចូលទៅក្នុងការិយាល័យឈ្មោះបោះឆ្នោត លើកលែងតែមានការស្នើសុំឱ្យជួយដោះស្រាយបាតុភាព ឬហេតុការណ៍អសន្តិសុខអ្វីមួយ ដែលកើតមានជាយថាហេតុ ឬក៏នៅក្នុងករណីមានគ្រោះមហន្តរាយធ្ងន់ធ្ងរជាក់ស្តែង។

- ភ្នាក់ងារសន្តិសុខបោះឆ្នោត មិនត្រូវអនុញ្ញាតឱ្យជនណាប្រដាប់ដោយអាវុធ ឬមានលាក់អាវុធ គ្រឿងផ្ទុះ ឬគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងខ្លួនចូលក្នុង ឬឈរក្បែរការិយាល័យចុះឈ្មោះបោះឆ្នោត ជាដាច់ខាត។

- ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវស្ថិតនៅជិតការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីត្រៀមខ្លួនបំពេញភារកិច្ចនៅក្នុងករណីមានសំណូមពរស្នើសុំឱ្យជួយការពារសន្តិសុខ រក្សាសណ្តាប់ធ្នាប់ និងរបៀបរៀបរយសម្រាប់ការិយាល័យចុះឈ្មោះបោះឆ្នោតដែលខ្លួនកំពុងការពារ។

- ករណីមានសំណូមពរពីក្រុមចុះឈ្មោះបោះឆ្នោត ឬពេលមានគ្រោះមហន្តរាយធ្ងន់ធ្ងរជាក់ស្តែង ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវបានបំពាក់អាវុធសមស្រប ឬ/និងភ្នាក់ងារសង្គ្រោះ (មានក្រុមពន្លត់អគ្គិភ័យ ឬក្រុមបុគ្គលិកពេទ្យ) អាចចូលអន្តរាគមន៍ ឬជួយសង្គ្រោះនៅពេលនោះបាន។

- កម្លាំងត្រៀមអន្តរាគមន៍ភូមិសាស្ត្រខាងក្រៅ ចំនួន ២០នាក់ ដែលឈរជើងក្នុងក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវយកចិត្តទុកដាក់ការពារ និងផ្តល់សុវត្ថិភាពដល់មុខសញ្ញា និងគោលដៅសំខាន់ៗ ដោយត្រូវតាមដាន **ដោយត្រូវមានផែនការល្បាត** ក្តាប់ជាប់សភាពការណ៍ សន្តិសុខនៅតាមភូមិសាស្ត្ររបស់ខ្លួន និងត្រៀមលក្ខណៈរួចជាស្រេចសម្រាប់ចូលរួមអន្តរាគមន៍ទាន់ពេលវេលាចំពោះហេតុការណ៍ ឬក៏ឧបទ្ទវហេតុផ្សេងៗ ដែលអាចកើតមានជាថៃដន្យ។

- បន្ទាប់ពីចប់ការចុះឈ្មោះបោះឆ្នោត ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវប្រមូលផ្តុំកម្លាំងសរុប មធ្យោបាយសរុប និងបន្តត្រៀមលក្ខណៈនៅតាមគោលដៅរបស់ខ្លួនសម្រាប់រយៈពេលនៃដំណើរការនីតិវិធីដោះស្រាយបណ្តឹងទាក់ទងការចុះឈ្មោះបោះឆ្នោត រហូតដល់ការចប់ការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតផ្លូវការដោយ **គ.ជ.ប**។

- ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវចាត់កម្លាំងឱ្យចូលរួមការពារគ្រប់ទីកន្លែងរក្សាទុក ក្បួន ឬការដឹកជញ្ជូនសម្ភារ បរិក្ខារ និងឯកសារចុះឈ្មោះបោះឆ្នោតទៅកាន់គោលដៅដែលត្រូវបានកំណត់ប្រកបដោយសុវត្ថិភាពខ្ពស់ និងគ្មានការរអាក់រអួល។

- ក្រុមការីវិទ្យុទាក់ទង ត្រូវមានភារកិច្ចប្រចាំការ ២៤ ម៉ោងលើ ២៤ម៉ោង ដើម្បីត្រៀមទទួល ផ្លាស់ប្តូរផ្សព្វផ្សាយ និងបែងចែករាល់ព័ត៌មានឬរបាយការណ៍ផ្នែកសន្តិសុខ និងការងារចាំបាច់ផ្សេងៗទៀត សំដៅបម្រើដល់គ្រប់យន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងភ្នាក់ងារសន្តិសុខបោះឆ្នោតទាំងអស់។

- កម្លាំងត្រៀមអន្តរាគមន៍ភូមិសាស្ត្រខាងក្រៅ និងកម្លាំងត្រៀមអន្តរាគមន៍នៅនឹងកន្លែង ត្រូវមានភារកិច្ចតាមដាន និងក្តាប់ជាប់សភាពការណ៍សន្តិសុខនៅក្នុងភូមិសាស្ត្ររបស់ខ្លួន និងត្រៀមខ្លួនជារួចស្រេចសម្រាប់ការចូលរួមជួយអន្តរាគមន៍ទាន់ពេលវេលា៕

# ឧបសម្ព័ន្ធ ២

## ការរៀបចំកម្លាំង និងភារកិច្ចរបស់ភ្នាក់ងារសន្តិសុខបោះឆ្នោត ដើម្បីការពារការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៦ ឆ្នាំ២០២៧ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៨ ឆ្នាំ២០២៨

គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្តក្នុងនាមជាយន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ក្រោមជាតិ ឬថ្នាក់រាជធានី ខេត្ត ដែលមានស្នងការដ្ឋាននគរបាលជាជំនួយការ ត្រូវសហការជាមួយ **លជ.ឧប** ឬ **គជ.ឧប** ដើម្បីត្រៀមរៀបចំភ្នាក់ងារសន្តិសុខបោះឆ្នោតតាមគោលការណ៍កំណត់ ដូចតទៅៈ

**I. អំពីការរៀបចំភ្នាក់ងារសន្តិសុខបោះឆ្នោត**

**១. កម្លាំងការពារនៅពេលឃោសនាបោះឆ្នោត**

**ក-គោលដៅការពារ** : នៅទូទាំងប្រទេស

**ខ-ចំនួនកម្លាំងដែលត្រូវប្រើប្រាស់**

: ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់នីមួយៗ ចំនួន ៧នាក់

: អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌនីមួយៗ ចំនួន ២០នាក់

: មូលដ្ឋានកងរាជអាវុធហត្ថក្រុង ស្រុក ខណ្ឌនីមួយៗ ចំនួន ១០នាក់

: ផ្នែកសឹករងក្រុង ស្រុក ខណ្ឌនីមួយៗ ចំនួន ១០នាក់

**គ-រយៈពេលការពារ** : ១៤ថ្ងៃ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

: ២១ថ្ងៃ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

**២. កម្លាំងការពារនៅពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

**២.១ កម្លាំងការពារទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប)**

**ក-គោលដៅការពារ** : គ្រប់ទីស្នាក់ការរបស់ **គឃ.សប**

**ខ-ចំនួនកម្លាំងដែលត្រូវប្រើប្រាស់**

: ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់នីមួយៗ ចំនួន ២នាក់

**គ-រយៈពេលការពារ** : ៥ថ្ងៃ (២ថ្ងៃមុនថ្ងៃបោះឆ្នោត ថ្ងៃបោះឆ្នោត និង២ថ្ងៃក្រោយថ្ងៃបោះឆ្នោត)

**២.២ កម្លាំងការពារការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត**

**ក-គោលដៅការពារ** : ការិយាល័យបោះឆ្នោតទាំងអស់នៅទូទាំងប្រទេស

**ខ-ចំនួនកម្លាំងដែលត្រូវប្រើប្រាស់**

: កម្លាំងនៃភ្នាក់ងារសន្តិសុខបោះឆ្នោត ចំនួនមិនលើសពី ៣នាក់ ការពារនៅតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ

**គ-រយៈពេលការពារ** : ២ថ្ងៃ (១ថ្ងៃមុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត)

**២.៣ កម្លាំងត្រៀមអន្តរាគមន៍ភូមិសាស្ត្រខាងក្រៅ ក្នុងក្រុង ស្រុក ខណ្ឌ**

**ក-គោលដៅការពារ** : គ្រប់ក្រុង ស្រុក ខណ្ឌ

ខ-ចំនួនកម្លាំងដែលត្រូវប្រើប្រាស់

: មូលដ្ឋានកងរាជអាវុធហត្ថក្រុង ស្រុក ខណ្ឌនីមួយៗ ចំនួន ១០នាក់

: ផ្នែកសឹករងក្រុង ស្រុក ខណ្ឌនីមួយៗ ចំនួន ១០នាក់

គ-រយៈពេលការពារ : ៥ថ្ងៃ (២ថ្ងៃមុនថ្ងៃបោះឆ្នោត ថ្ងៃបោះឆ្នោត និង ២ថ្ងៃក្រោយថ្ងៃបោះឆ្នោត)

**៣. ក្រុមការីវិទ្យុទាក់ទង**

ក-គោលដៅប្រចាំការ : គ្រប់រាជធានី ខេត្ត និង គ្រប់ក្រុង ស្រុក ខណ្ឌ

ខ-ចំនួនកម្លាំងដែលត្រូវប្រើប្រាស់

: គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្តនីមួយៗ ចំនួន ៦នាក់

: គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ ចំនួន ៤នាក់

គ-រយៈពេលប្រចាំការ : គិតចាប់ពីពេលផ្តើមការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឬ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ រហូតចប់ការប្រកាសលទ្ធផលបោះឆ្នោតជាផ្លូវការនៃការបោះឆ្នោតនីមួយៗ

**៤. កម្លាំងត្រៀមអន្តរាគមន៍នៅនឹងកន្លែង**

ក-គោលដៅត្រៀម : គ្រប់រាជធានី ខេត្ត នៅទូទាំងប្រទេស

ខ-ចំនួនកម្លាំងដែលត្រូវប្រើប្រាស់

: អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ចំនួន **២០០នាក់**

: អគ្គស្នងការដ្ឋាននគរបាលជាតិ ចំនួន **២០០នាក់**

: បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ចំនួន **២០០នាក់**

: បញ្ជាការដ្ឋានយោធភូមិភាគទាំង ៦ ដែលក្នុងមួយយោធភូមិភាគ ចំនួន ១០០នាក់)

គ-រយៈពេលត្រៀម : គិតចាប់ពីពេលផ្តើមការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឬ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ រហូតចប់ការប្រកាសលទ្ធផលបោះឆ្នោតជាផ្លូវការនៃការបោះឆ្នោតនីមួយៗ

**II. អំពីភារកិច្ចរបស់ភ្នាក់ងារសន្តិសុខបោះឆ្នោត**

**១. ភារកិច្ចរបស់កម្លាំងការពារការឃោសនាបោះឆ្នោត**

ក្នុងយុទ្ធនាការឃោសនាបោះឆ្នោត ផ្អែកតាមសំណើ និងប្រតិទិនសម្រាប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវចាត់ចែងកម្លាំងការពារក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ និងជុំវិញបរិវេណនៃការជួបប្រជុំ ឬការឃោសនាជាសាធារណៈ ដោយរក្សាឱ្យបាននូវបរិយាកាសនយោបាយអព្យាក្រឹត គ្មានការបំភិតបំភ័យ ការគំរាមកំហែង និងអំពើហិង្សា ឬការបង្កនូវការអុកឡុក ការរំខាន ឬក៏ការចលាចលផ្សេងៗ។

ភ្នាក់ងារសន្តិសុខបោះឆ្នោត មិនត្រូវទៅឈរក្បែរ ឬដើរកៀកពេកនឹងទីតាំង ឬក្បួនឃោសនាបោះឆ្នោត ឬក៏ស្ថិតនៅក្នុងបរិវេណនៃអង្គពិធីឃោសនាបោះឆ្នោតនានា ដោយត្រូវធានាចំពោះគ្រប់គណបក្សនយោបាយឈរឈ្មោះ និងបេក្ខជនគ្រប់រូបនូវសិទ្ធិស្មើៗគ្នាក្នុងការទទួលបានសេវាសន្តិសុខ សុវត្ថិភាព ការរៀបចំសណ្តាប់ធ្នាប់ និងរបៀបរៀបរយពីអាជ្ញាធរមានសមត្ថកិច្ច។

ភ្នាក់ងារសន្តិសុខបោះឆ្នោតដែលកំពុងបំពេញភារកិច្ច ត្រូវប្រកាន់ជំហរអព្យាក្រឹតដោយមិនត្រូវចូលរួម ឬក៏ប្រឆាំងចំពោះសកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយឈរឈ្មោះ ឬបេក្ខជនណាមួយដាច់ខាត។

**២. ភារកិច្ចរបស់កម្លាំងការពារការបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

ភ្នាក់ងារសន្តិសុខបោះឆ្នោត (**ចំនួនមិនលើសពី ៣នាក់**) ពាក់ប្រឡង់ដែសន្តិសុខរបស់ **គ.ជ.ប** ត្រូវទៅកាន់ការិយាល័យបោះឆ្នោតឱ្យបានមុនពេលចាប់ផ្តើមការបោះឆ្នោត ដើម្បីពិនិត្យទីតាំង ស្ថានការណ៍សន្តិសុខ ឱ្យបានគ្រប់ជ្រុងជ្រោយ និងអនុវត្តតាមគោលការណ៍ណែនាំដូចតទៅ៖

- មិនត្រូវជ្រៀតជ្រៀកការងារបោះឆ្នោត ឬចូលទៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយគ្មានការអនុញ្ញាតក្នុងពេលបោះឆ្នោត ឬពេលរាប់សន្លឹកឆ្នោត លើកលែងតែមានការស្នើសុំពីប្រធានការិយាល័យ ដើម្បីអន្តរាគមន៍ ឬដោះស្រាយបាតុភាព ការអុកឡុក ឬការរំខានផ្សេងៗ
- មិនត្រូវអនុញ្ញាតឱ្យជនណាប្រដាប់ដោយអាវុធ ឬមានលាក់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងខ្លួនចូលទៅក្នុង ឬឈរក្បែរការិយាល័យបានជាដាច់ខាត
- ត្រូវស្ថិតនៅជិតការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដើម្បីត្រៀមខ្លួនបំពេញភារកិច្ចក្នុងករណីមានសំណូមពរពីប្រធានការិយាល័យ ក្នុងគោលបំណងស្នើសុំឱ្យជួយការពារសន្តិសុខ សុវត្ថិភាព និងរៀបចំសណ្តាប់ធ្នាប់របៀបរៀបរយការិយាល័យនោះ
- ករណីមានសំណូមពរពីប្រធានការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ឬពេលមានគ្រោះមហន្តរាយធ្ងន់ធ្ងរជាក់ស្តែង កម្លាំងអាចត្រូវបានបំពាក់អាវុធសមស្រប ឬភ្នាក់ងារសង្គ្រោះ (ក្រុមពន្លត់អគ្គិសភ័យ ឬក្រុមបុគ្គលិកពេទ្យ) អាចចូលធ្វើអន្តរាគមន៍ ឬជួយសង្គ្រោះនៅក្នុងការិយាល័យកើតហេតុនោះបាន។

កម្លាំងត្រៀមអន្តរាគមន៍ភូមិសាស្ត្រខាងក្រៅ ត្រូវតាមដាន និងក្តាប់ជាប់សភាពការណ៍សន្តិសុខនៅក្នុងភូមិសាស្ត្ររបស់ខ្លួន និងត្រៀមខ្លួនជាស្រេចសម្រាប់ការចូលរួមជួយអន្តរាគមន៍ទាន់ពេលវេលា។

**៣. ភារកិច្ចរបស់កម្លាំងការពារការដឹកជញ្ជូនសម្ភារ បរិក្ខារ និងឯកសារបោះឆ្នោត**

តាមការស្នើសុំពី **គ.ជ.ប** ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវយកចិត្តទុកដាក់ចាត់កម្លាំងឱ្យចូលរួមការពារគ្រប់ទីកន្លែងរក្សាទុក ក្បួន ឬការដឹកជញ្ជូនសម្ភារ បរិក្ខារ និងឯកសារបោះឆ្នោត ដូចជា៖ សន្លឹកឆ្នោត កំណត់ហេតុរាប់សន្លឹកឆ្នោត និងកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្នតាមការិយាល័យបោះឆ្នោតនីមួយៗទៅកាន់គោលដៅ ដែលត្រូវបានកំណត់ប្រកបដោយសុវត្ថិភាព និងគ្មានការរអាក់រអួល។

**៤. ភារកិច្ចរបស់ក្រុមការីវិទ្យុទាក់ទង**

ក្រុមការីវិទ្យុទាក់ទង ត្រូវមានភារកិច្ចប្រចាំការ ២៤ម៉ោង លើ ២៤ម៉ោង ដើម្បីត្រៀមទទួល ផ្លាស់ប្តូរ ផ្សព្វផ្សាយ និងបែងចែករាល់ព័ត៌មាន ឬរបាយការណ៍ផ្នែកសន្តិសុខ និងការងារចាំបាច់ផ្សេងៗទៀត សំដៅបម្រើដល់គ្រប់យន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងភ្នាក់ងារសន្តិសុខបោះឆ្នោតទាំងអស់ និងគ្រប់ដំណាក់កាលនៃការបោះឆ្នោតនីមួយៗ។

ក្រុមការវិទ្យុទាក់ទងគ្រប់ផ្នែកគ្រប់ថ្នាក់ ត្រូវចាប់ផ្តើមសកម្មភាពរបស់ខ្លួន ស្របពេលនឹងដំណើរការចាប់ផ្តើមនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ តាមនីតិកាល និងអាណត្តិ រហូតដល់ចប់ការប្រកាសលទ្ធផលបោះឆ្នោតជាផ្លូវការនៃការបោះឆ្នោតនីមួយៗ ជាស្ថាពរ។

**៥. ភារកិច្ចរបស់កម្លាំងត្រៀមអន្តរាគមន៍នៅនឹងកន្លែង**

កម្លាំងត្រៀមអន្តរាគមន៍នៅនឹងកន្លែង ត្រូវមានភារកិច្ចប្រចាំការ ២៤ម៉ោង លើ ២៤ម៉ោង ដើម្បីត្រៀមអន្តរាគមន៍ចាំបាច់ផ្សេងៗ ស្របពេលនឹងដំណើរការចាប់ផ្តើមនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រតាមនីតិកាល និងអាណត្តិរហូតដល់ចប់ការប្រកាសលទ្ធផលបោះឆ្នោតជាផ្លូវការនៃការបោះឆ្នោតនីមួយៗ ជាស្ថាពរ។

# ឧបសម្ព័ន្ធ ៣

# ការរៀបចំកម្លាំង និងភារកិច្ចរបស់ភ្នាក់ងារសន្តិសុខបោះឆ្នោត ដើម្បីការពារការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៥ ឆ្នាំ២០២៩ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៦ ឆ្នាំ២០៣០

គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្នុងនាមជាយន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ក្រោមជាតិ ឬថ្នាក់រាជធានី ខេត្ត ដែលមានស្នងការដ្ឋាននគរបាលជាជំនួយការ ត្រូវសហការជាមួយ **លធ.ខប** ឬ **គធ.ខប** ដើម្បីត្រៀមរៀបចំភ្នាក់ងារសន្តិសុខបោះឆ្នោត តាមគោលការណ៍កំណត់ដូចតទៅៈ

## I. អំពីការរៀបចំភ្នាក់ងារសន្តិសុខបោះឆ្នោត

### ១. កម្លាំងការពារនៅពេលស្រង់ឈ្មោះរៀបចំបញ្ជីបោះឆ្នោត

**ក-គោលដៅការពារ** : គ្រប់ការិយាល័យចុះឈ្មោះបោះឆ្នោត នៅតាមសាលាឃុំ សង្កាត់ និងនៅអគ្គលេខាធិការដ្ឋានរដ្ឋសភា ដើម្បីស្រង់ឈ្មោះរៀបចំបញ្ជីបោះឆ្នោតសម្រាប់ការបោះឆ្នោតអសកល ជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលមានអ្នកបោះឆ្នោត គឺជាតំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាសង្កាត់ក្នុងតំណែង។ អង្គបោះឆ្នោត នៃមណ្ឌលនីមួយៗ គឺជាតំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងតំណែង ទាំងអស់នៅក្នុងមណ្ឌលបោះឆ្នោតនោះ ឬ

: គ្រប់ការិយាល័យចុះឈ្មោះបោះឆ្នោត នៅតាមសាលាឃុំ សង្កាត់សម្រាប់ការបោះឆ្នោតអសកល ជ្រើសរើសក្រុមប្រឹក្សា ដែលអ្នកបោះឆ្នោត គឺមានតែសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងមុខតំណែងប៉ុណ្ណោះ

**ខ-ចំនួនកម្លាំងដែលត្រូវប្រើប្រាស់**

: ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់នីមួយៗ ចំនួន ២នាក់

**គ-រយៈពេលការពារ** : ១៦ថ្ងៃ (រយៈពេលនេះអាចកំណត់ផ្សេងពីនេះ តាមការសម្រេចរបស់ **គ.ជ.ប**)

### ២. កម្លាំងការពារនៅពេលឃោសនាបោះឆ្នោត

**ក-គោលដៅការពារ** : គ្រប់រាជធានី ខេត្ត គ្រប់ក្រុង ស្រុក ខណ្ឌ និងគ្រប់ឃុំ សង្កាត់នៅទូទាំងប្រទេស

**ខ-ចំនួនកម្លាំងដែលត្រូវប្រើប្រាស់**

: ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់នីមួយៗ ចំនួន ៧នាក់

: អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌនីមួយៗ ចំនួន ១០នាក់

: មូលដ្ឋានកងរាជអាវុធហត្ថក្រុង ស្រុក ខណ្ឌនីមួយៗ ចំនួន ១០នាក់

**គ-រយៈពេលការពារ** : ១៤ថ្ងៃ សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

: ៨ថ្ងៃ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

## ៣. កម្លាំងការពារនៅពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត

### ៣.១ កម្លាំងការពារការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

**ក-គោលដៅការពារ** : គ្រប់ការិយាល័យ សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

: គ្រប់ការិយាល័យ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

**ខ-ចំនួនកម្លាំងដែលត្រូវប្រើប្រាស់**

: កម្លាំងនៃភ្នាក់ងារសន្តិសុខបោះឆ្នោត ចំនួនមិនលើសពី ៣នាក់ ការពារនៅតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ

**គ-រយៈពេលការពារ** : ២ថ្ងៃ (១ថ្ងៃមុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត)

### ៣.២ កម្លាំងត្រៀមអន្តរាគមន៍ភូមិសាស្ត្រខាងក្រៅ ក្នុងក្រុង ស្រុក ខណ្ឌ

**ក-គោលដៅការពារ** : គ្រប់ក្រុង ស្រុក ខណ្ឌ

**ខ-ចំនួនកម្លាំងដែលត្រូវប្រើប្រាស់**

: អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌនីមួយៗ ចំនួន ២០នាក់

: មូលដ្ឋានកងរាជអាវុធហត្ថក្រុង ស្រុក ខណ្ឌនីមួយៗ ចំនួន ១០នាក់

**គ-រយៈពេលការពារ** : ៥ថ្ងៃ (២ថ្ងៃមុនថ្ងៃបោះឆ្នោត ថ្ងៃបោះឆ្នោត និង ២ថ្ងៃក្រោយថ្ងៃបោះឆ្នោត)

## ៤. ក្រុមការីវិទ្យុទាក់ទង

**ក-គោលដៅប្រចាំការ** : គ្រប់រាជធានី ខេត្ត គ្រប់ក្រុង ស្រុក ខណ្ឌ និង គ្រប់ឃុំ សង្កាត់ នៅទូទាំងប្រទេស

**ខ-ចំនួនកម្លាំងដែលត្រូវប្រើប្រាស់**

: គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្តនីមួយៗ ចំនួន ៦នាក់

: គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ ចំនួន ៤នាក់

**គ-រយៈពេលប្រចាំការ** : គិតចាប់ពីពេលផ្តើមការស្រង់ឈ្មោះរៀបចំបញ្ជីបោះឆ្នោត ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ឬការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ហូតចប់ការប្រកាសលទ្ធផលបោះឆ្នោតជាផ្លូវការនៃការបោះឆ្នោតនីមួយៗ

## ៥. កម្លាំងត្រៀមអន្តរាគមន៍នៅនឹងកន្លែង

**ក-គោលដៅត្រៀម** : គ្រប់រាជធានី ខេត្ត នៅទូទាំងប្រទេស

**ខ-ចំនួនកម្លាំងដែលត្រូវប្រើប្រាស់**

: អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ចំនួន <u>២០០នាក់</u>

: អគ្គស្នងការដ្ឋាននគរបាលជាតិ ចំនួន <u>២០០នាក់</u>

: បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ចំនួន <u>២០០នាក់</u>

: បញ្ជាការដ្ឋានយោធភូមិភាគទាំង ៦ ដែលក្នុងមួយយោធភូមិភាគ ចំនួន ១០០នាក់)

**គ-រយៈពេលត្រៀម** : គិតចាប់ពីពេលផ្ដើមការស្រង់ឈ្មោះរៀបចំបញ្ជីបោះឆ្នោត ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ឬការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រហូតចប់ការប្រកាសលទ្ធផលបោះឆ្នោតជាផ្លូវការនៃការបោះឆ្នោតនីមួយៗ

## IV. អំពីភារកិច្ចរបស់ភ្នាក់ងារសន្តិសុខបោះឆ្នោត

### ១. ភារកិច្ចរបស់កម្លាំងការពារនៅពេលស្រង់ឈ្មោះអ្នកបោះឆ្នោត

សម្រាប់ការស្រង់ឈ្មោះអ្នកបោះឆ្នោតអសកល ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវសហការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ (**កបឃ.ស**) ដើម្បីបំពេញភារកិច្ចតាមការណែនាំដូចខាងក្រោម៖

- ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវចាត់វិធានការការពារទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ឬកន្លែងកំណត់សម្រាប់ចុះឈ្មោះបោះឆ្នោត។
- ភ្នាក់ងារសន្តិសុខបោះឆ្នោត ចំនួន ២នាក់ ដែលការពារការិយាល័យចុះឈ្មោះបោះឆ្នោត ស្រង់ឈ្មោះអ្នកបោះឆ្នោត ត្រូវមានមុខនៅមុនម៉ោង ៧:០០ព្រឹក ដើម្បីពិនិត្យទីតាំងការិយាល័យស្ថានភាពសន្តិសុខ និងត្រូវចាត់វិធានការការពារឱ្យបានតឹងរ៉ឹងបំផុត។
- ក្នុងពេលបំពេញភារកិច្ច ភ្នាក់ងារសន្តិសុខបោះឆ្នោត មិនត្រូវចូលទៅក្នុងការិយាល័យ លើកលែងតែមានការស្នើសុំ ដើម្បីឱ្យជួយដោះស្រាយរាល់បាតុភាព ឬហេតុការណ៍អសន្តិសុខអ្វីមួយ ដែលកើតមានជាយថាហេតុ ឬក៏នៅក្នុងករណីមានគ្រោះមហន្តរាយធ្ងន់ធ្ងរជាក់ស្ដែង។
- ភ្នាក់ងារសន្តិសុខបោះឆ្នោត មិនត្រូវអនុញ្ញាតឱ្យជនណាប្រដាប់ដោយអាវុធ ឬមានលាក់អាវុធ គ្រឿងផ្ទុះ ឬគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងខ្លួន ចូលក្នុង ឬឈរក្បែរការិយាល័យជាដាច់ខាត។
- ភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវស្ថិតនៅជិតការិយាល័យ ដើម្បីត្រៀមខ្លួនបំពេញភារកិច្ច នៅក្នុងករណីមានសំណូមពរស្នើសុំឱ្យជួយការពារសន្តិសុខ រក្សាសណ្ដាប់ធ្នាប់ និងរបៀបរៀបរយ។
- ករណីមានសំណូមពរ ឬពេលមានគ្រោះមហន្តរាយធ្ងន់ធ្ងរជាក់ស្ដែង ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវបានបំពាក់អាវុធសមស្រប ឬ/និងភ្នាក់ងារសង្គ្រោះ (ក្រុមពន្លត់អគ្គិភ័យ ឬក្រុមបុគ្គលិកពេទ្យ) អាចចូលអន្តរាគមន៍ ឬជួយសង្គ្រោះនៅពេលនោះបាន។

### ២. ភារកិច្ចរបស់កម្លាំងការពារការឃោសនាបោះឆ្នោត

តាមសំណើ និងប្រតិទិនសម្រាប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនៅក្នុងរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវចាត់ចែងកម្លាំងការពារក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ និងជុំវិញបរិវេណនៃការជួបប្រជុំ ឬការឃោសនាជាសាធារណៈ ដោយរក្សាឱ្យបាននូវបរិយាកាសនយោបាយអព្យាក្រឹត គ្មានការបំភិតបំភ័យ គ្មានការគំរាមកំហែង និងគ្មានអំពើហិង្សា ឬការបង្កនូវការអុកឡុក ការរំខាន ឬការចលាចលផ្សេងៗ។

ភ្នាក់ងារសន្តិសុខបោះឆ្នោតមិនត្រូវទៅឈរក្បែរ ឬដើរកៀកពេកនឹងក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ និងជុំវិញបរិវេណនៃការជួបប្រជុំ ឬការឃោសនាជាសាធារណៈដោយត្រូវធានាចំពោះគ្រប់គណបក្សនយោបាយឈរឈ្មោះនិងបេក្ខជនគ្រប់រូបនូវសិទ្ធិស្មើៗគ្នាក្នុងការទទួលបាននូវសេវាសន្តិសុខ សុវត្ថិភាព និងការរៀបចំសណ្ដាប់ធ្នាប់របៀបរៀបរយពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច។

ភ្នាក់ងារសន្តិសុខបោះឆ្នោតដែលកំពុងបំពេញភារកិច្ច ត្រូវប្រកាន់ជំហរអព្យាក្រឹត និងមិនត្រូវចូលរួមឬប្រឆាំងនឹងសកម្មភាពឃោសនាបោះឆ្នោតរបស់បេក្ខជន និងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតណាមួយជាដាច់ខាត។

**៣. ភារកិច្ចរបស់កម្លាំងការពារការបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

ភ្នាក់ងារសន្តិសុខបោះឆ្នោតចំនួន ៣នាក់ ដែលមានពាក់ប្រឡង់ដៃសន្តិសុខរបស់ **គ.ជ.ប** ត្រូវទៅកាន់ការិយាល័យបោះឆ្នោត ឱ្យបានមុនពេលចាប់ផ្តើមនៃការបោះឆ្នោត ដើម្បីពិនិត្យទីតាំង និងស្ថានការណ៍សន្តិសុខឱ្យបានគ្រប់ជ្រុងជ្រោយ ដោយអនុវត្តតាមគោលការណ៍ដូចតទៅៈ

- មិនត្រូវជ្រៀតជ្រែកការងារបោះឆ្នោត ឬចូលក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយគ្មានការអនុញ្ញាត ក្នុងពេលបោះឆ្នោត ឬរាប់សន្លឹកឆ្នោត លើកលែងតែមានការស្នើសុំពីប្រធានការិយាល័យដើម្បីអន្តរាគមន៍ ឬដោះស្រាយបាតុភាព ការអុកឡុក ឬការរំខានផ្សេងៗ
- មិនត្រូវអនុញ្ញាតឱ្យជនណាប្រដាប់អាវុធ ឬមានលាក់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងខ្លួនចូលទៅក្នុង ឬក៏ឈរក្បែរការិយាល័យបានជាដាច់ខាត
- ត្រូវស្ថិតនៅជិតការិយាល័យដើម្បីត្រៀមខ្លួនបំពេញភារកិច្ច នៅក្នុងករណីមានសំណូមពរពីប្រធានការិយាល័យ ក្នុងគោលបំណងស្នើសុំឱ្យជួយការពារសន្តិសុខ និងការរៀបចំសណ្តាប់ធ្នាប់របៀបរៀបរយ
- ករណីមានសំណូមពរពីប្រធានការិយាល័យ ឬពេលមានគ្រោះមហន្តរាយធ្ងន់ធ្ងរជាក់ស្តែង កម្លាំងការពារអាចត្រូវបានបំពាក់អាវុធសមស្រប ឬភ្នាក់ងារសង្គ្រោះ (ក្រុមពន្លត់អគ្គិភ័យ ឬបុគ្គលិកពេទ្យ) អាចចូលធ្វើអន្តរាគមន៍ ឬក៏ជួយសង្គ្រោះនៅក្នុងការិយាល័យដែលកើតហេតុនោះបាន។

កម្លាំងត្រៀមអន្តរាគមន៍ភូមិសាស្ត្រខាងក្រៅ ត្រូវតាមដាន និងក្តាប់ជាប់សភាពការណ៍សន្តិសុខនៅក្នុងភូមិសាស្ត្ររបស់ខ្លួន និងត្រៀមខ្លួនរួចជាស្រេចសម្រាប់ការចូលរួមជួយអន្តរាគមន៍នានាបានទាន់ពេលវេលា។

គ្រប់ដំណាក់កាលនៃការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិអសកលតាមនីតិកាល និងអាណត្តិនីមួយៗ ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវយកចិត្តទុកដាក់ចាត់ចែងកម្លាំងឱ្យចូលរួមការពារគ្រប់ទីកន្លែងរក្សាទុក ក្បួន ឬការដឹកជញ្ជូនសម្ភារ បរិក្ខា និងឯកសារបោះឆ្នោត ដូចជាៈ សន្លឹកឆ្នោត កំណត់ហេតុរាប់សន្លឹកឆ្នោត និងកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្នតាមការិយាល័យបោះឆ្នោតនីមួយៗ ទៅកាន់គោលដៅដែលត្រូវបានកំណត់ប្រកបដោយសុវត្ថិភាព និងគ្មានការរអាក់រអួល។

**៤. ភារកិច្ចរបស់ក្រុមការីវិទ្យុទាក់ទង**

ក្រុមការីវិទ្យុទាក់ទងត្រូវមានភារកិច្ចប្រចាំការ ២៤ម៉ោង លើ ២៤ម៉ោង ដើម្បីត្រៀមទទួល ផ្លាស់ប្តូរ និងផ្សព្វផ្សាយបែងចែករាល់ព័ត៌មាន ឬរបាយការណ៍ផ្នែកសន្តិសុខ និងការងារចាំបាច់ផ្សេងទៀត សំដៅបម្រើឱ្យគ្រប់យន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោតទាំងអស់។

ក្រុមការីវិទ្យុទាក់ទងគ្រប់ផ្នែកគ្រប់ថ្នាក់ត្រូវចាប់ផ្តើមសកម្មភាពរបស់ខ្លួន ស្របពេលនឹងដំណើរការចាប់ផ្តើមការស្រង់ឈ្មោះរៀបចំបញ្ជីបោះឆ្នោត ការបោះឆ្នោតអសកល ជ្រើសតាំងសមាជិកព្រឹទ្ធសភា ឬការបោះឆ្នោតអសកលជ្រើសរើសក្រុមប្រឹក្សា រហូតចប់ការប្រកាសលទ្ធផលបោះឆ្នោតជាផ្លូវការនៃការបោះឆ្នោតតាមនីតិកាល អាណត្តិនីមួយៗ ជាស្ថាពរ។

**៥. ភារកិច្ចរបស់កម្លាំងត្រៀមអន្តរាគមន៍នៅនឹងកន្លែង**

កម្លាំងត្រៀមអន្តរាគមន៍នៅនឹងកន្លែង ត្រូវមានភារកិច្ចប្រចាំការ ២៤ម៉ោង លើ ២៤ម៉ោង ដើម្បីត្រៀមអន្តរាគមន៍ក្នុងករណីចាំបាច់ផ្សេងៗ ស្របពេលនឹងដំណើរការចាប់ផ្តើមការស្រង់ឈ្មោះរៀបចំបញ្ជីបោះឆ្នោត ការបោះឆ្នោតអសកល ជ្រើសតាំងសមាជិកព្រឹទ្ធសភា ឬការបោះឆ្នោតអសកល ជ្រើសរើសក្រុមប្រឹក្សា រហូតចប់ការប្រកាសលទ្ធផលបោះឆ្នោតជាផ្លូវការនៃការបោះឆ្នោតតាមនីតិកាល អាណត្តិនីមួយៗ ជាស្ថាពរ។